AFESIP

AGIR POUR LES FEMMES
EN SITUATION PRÉCAIRE

# របាយការណ៍ប្រចាំឆ្នាំ ២០២២

## អង្គការ អាហ្វេស៊ីប កម្ពុជា

**H/P and telegram:**
(855) 61 601 601
(855) 12 888 840
E-mail: info@afesip.org
Www: afesip.org

**Mailing Address:**
P.O.Box 2089
Phnom Penh 3
Cambodia.
CCC Box: 352-Cambodia.

# មាតិកា

៣ ស្ថាបនិក និងអគ្គនាយិកា
៤ អំពី អាហ្វេស៊ីប កម្ពុជា
៥ សកម្មភាពសំខាន់ៗប្រចាំខែ ក្នុងឆ្នាំ២០២២
៦ ភាពជោគជ័យរបស់យុវនារីទទួលផលពីកម្មវិធីយើង
៧ របាយការណ៍សង្ខេប
៨-១៨ អំពីសកម្មភាពការងារ
១៩ អំពីបុគ្គលិក និងការគ្រប់គ្រងគម្រោង
២០ ក្រុមប្រឹក្សាភិបាល និងម្ចាស់ជំនួយ
២១ ការបរិច្ចាគជាសម្ភារៈ



# សារពីស្ថាបនិក និងអគ្គនាយិកា

## មិត្តភក្ដិ និងអ្នកគាំទ្រទាំងអស់ ជាទីស្រឡាញ់ រាប់អាន!



នាងខ្ញុំមានសេចក្តីសោមនស្សរីករាយ សូមជម្រាបជូនរបាយការណ៍សកម្មភាពប្រចាំឆ្នាំ២០២២ ដល់លោក លោកស្រី នាងកញ្ញាដូចខាងក្រោម។ របាយការណ៍នេះបង្ហាញអំពីសមិទ្ធផលសម្រេចបាន បញ្ហាប្រឈម និងវឌ្ឍនភាព។

យើងខ្ញុំមានហេតុផលជាច្រើន ដើម្បីឆ្លងកម្មវិធីស្នូលទាំង៤ ក្នុងការបន្តផ្តល់ជម្រកសុវត្ថិភាព ពិគ្រោះព្យាបាល សុខផ្លូវកាយ សុខភាពផ្លូវចិត្ត និងជំនួយផ្នែកច្បាប់ជូនកុមារីរងគ្រោះបានជាច្រើននាក់ លើសពីការរំពឹងទុករបស់យើងខ្ញុំនៅមណ្ឌលទំនុំ ថ្វីបើយើងជួបឧបសគ្គការរីករាលដាលជម្ងឺកូវីដ-១៩ក៏ដោយ យើងនៅតែបានផ្តល់ការអប់រំ និងបណ្តុះបណ្តាលដល់យុវនារី-កុមារី បានសមាហរណកម្មពួកគាត់ជាមួយការងារ និងការបង្កើតមុខរបរ បន្ទាប់ពីពួកគាត់បានបញ្ចប់ការសិក្សា ដោយការប្រើប្រាស់ជំនាញដែលពួកគាត់បានជ្រើសរើស និងបានបញ្ចូលសមាជិកថ្មីជាច្រើននាក់របស់កម្មវិធីបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ ក្នុងរយៈពេល១២ខែកន្លងមកនេះ។

ការសម្រេចបានលទ្ធផលល្អទាំងនេះ គឺមិនអាចធ្វើទៅបានដោយគ្មានការចូលរួម គាំទ្រពីអ្នកទាំងអស់គ្នាបានទេ ដូច្នេះយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកអស់គ្នា។ អង្គការ អាហ្វេស៊ីប កម្ពុជា មានមោទនភាពនឹងប្រតិបត្តិការមានតម្លាភាព និងគណនេយ្យភាពចំពោះម្ចាស់ជំនួយ និងអ្នកគាំទ្ររបស់យើង។ របាយការណ៍នេះបានបរិយាយលំអិតអំពីសកម្មភាពការងារឆ្នាំ២០២២ទាំងអស់ ក្នុងគោលបំណងបង្ហាញ អ្នកទាំងអស់គ្នាពីលទ្ធផលវិជ្ជមាន បានជួយជីវិតកុមារីរងគ្រោះជាច្រើននាក់ និងក្រុមគ្រួសារពួកគាត់ នៅក្នុងប្រទេសកម្ពុជា។

បេសកកម្មរបស់យើង នៅមិនទាន់ចប់ ហើយនឹងមិនចប់ទេ ដរាបណាកុមារីមិនទាន់មានសុវត្ថិភាពពីការរំលោភបំពាន។ កុមារីរងគ្រោះដ៏អង់អាចក្លាហានទាំងនេះ តម្រូវការ ផលប្រយោជន៍ និងបំណងប្រាថ្នារបស់ពួកគេ រមែងជាអាទិភាពចំបងគ្រប់ការងារដែលយើងធ្វើ គ្រប់កម្មវិធីយើងប្រតិបត្តិការ និងគ្រប់សកម្មភាពយើងអនុវត្ត។ ពីមួយថ្ងៃទៅមួយថ្ងៃ និងជារៀងរាល់ថ្ងៃ យើងត្រូវបានការលើកទឹកចិត្ត និងការជំរុញដោយភាពក្លាហាន និងភាពរឹងមាំរបស់ពួកគាត់។

យើងលើកទឹកចិត្តជនរងគ្រោះឱ្យក្លាយជាអតីតជនរងគ្រោះ និងលើកទឹកចិត្តអតីតជនរងគ្រោះឱ្យក្លាយជាផ្នែកមួយនៃដំណោះស្រាយ។ យើងបានដាក់ចេញទិសដៅឆ្នាំ២០១៨ ក្នុងរយៈពេល១០ឆ្នាំខាងមុខ ៩០%នៃបុគ្គលិកយើងត្រូវតែជាអតីតជនរងគ្រោះ។ ក្នុងឆ្នាំ២០២២ ៥៨%នៃបុគ្គលិកសរុបរបស់យើងជានារី ហើយ ៨០%នៃបុគ្គលិកនារីជាអតីតជនរងគ្រោះ។ អតីតជនរងគ្រោះគឺជាអ្នកបង្កើតការផ្លាស់ប្តូរដ៏អស្ចារ្យក្នុងវិស័យការងារនេះ ហើយពួកគាត់ក៏ជានិមិត្តរូបឱ្យជនរងគ្រោះដទៃយកគំរូតាម។

នាងខ្ញុំផ្ទាល់ ជាអតីតជនរងគ្រោះដោយការជួញដូរ ខ្ញុំបានបង្កើតអង្គការនេះឡើងកាលពី២៦ឆ្នាំមុន ក្នុងគោលបំណងជួយកុមារីដទៃទៀត រងការឈឺចាប់ជួបជោគវាសនាដែលនាងខ្ញុំបានឆ្លងកាត់ ខ្ញុំចង់ឱ្យសម្លេងរបស់ពួកគេ មានអនុភាព នឹងបានឮដល់ពិភពលោកនៅពេលពួកគេស្រែក ព្រោះថាវាជារឿងរាវជីវិតរបស់ពួកគេ។ នាងខ្ញុំសូមអរគុណជាថ្មីម្តងទៀត ដល់លោក លោកស្រី នាងកញ្ញាដែលបានអានរបាយការណ៍ សកម្មភាពប្រចាំឆ្នាំ២០២២នេះ ហើយនាងខ្ញុំសង្ឃឹមថាអ្នកទាំងអស់គ្នាបន្តជួយគាំទ្រការងាររបស់យើងខ្ញុំ ហើយនឹងជួយអំពាវនាវជាមួយយើងខ្ញុំទាំងអស់គ្នា ដើម្បីលុបបំបាត់គ្រប់ទម្រង់ នៃការជួញដូរមនុស្ស រំលោភបំពាន រំលោភសេពសន្ថវៈ និងទាសភាព។

ដោយក្ដីអាប់អានដ៏ស្មោះស្ម័គ្រពីនាងខ្ញុំ



**ម៉ម សុម៉ាលី**

# អំពី អាហ្វេស៊ីប កម្ពុជា

**អង្គការ អាហ្វេស៊ីប កម្ពុជា** បានបង្កើតឡើងនៅឆ្នាំ១៩៩៦ ដោយលោកស្រីម៉ម សុម៉ាលី លោកស្រីផ្ទាល់ជាជនរងគ្រោះដោយការជួញដូរ ក្នុងគោលបំណងប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

**ចក្ខុវិស័យ** ជាពិភពលោកមួយដែលកុមារមានសុវត្ថិភាពពីទាសភាព។

**ទិសដៅអង្គការ** ផ្តល់ការថែទាំ និងធានាបាននូវសិទ្ធិរបស់យុវនារី-កុមារីរងគ្រោះ និងងាយរងគ្រោះ ដោយអំពើទាសភាព តាមរយៈការស្តារនីតិសម្បទា ការអប់រំ បណ្តុះបណ្តាល និងសមាហរណកម្មដោយជោគជ័យ ត្រឡប់ទៅសង្គមវិញដោយឯករាជ្យភាពហិរញ្ញវត្ថុ និរន្តរភាព និងភាពថ្លៃថ្នូរ។ យើងអនុវត្តការងារនេះ ដោយជួយជ្រោមជ្រែង និងបង្ហាត់បង្រៀនពួកគាត់ អំពីឯករាជ្យភាពហិរញ្ញវត្ថុ តាមរយៈនិរន្តភាពមុខរបរ។ បន្ទាប់មកយើងស្វាគមន៍ លើកទឹកចិត្តឱ្យពួកគាត់ ក្លាយជាផ្នែកមួយរបស់បណ្តាញលើកកម្ពស់អតីតៈជនរងគ្រោះ ។

**ក្រុមគោលដៅ** កុមារីជនរងគ្រោះ  និងងាយរងគ្រោះ ដោយការជួញដូរ រំលោភបំពាន និង កេងប្រវ័ញ្ចផ្លូវភេទ។

## កម្មវិធីយើង



## សកម្មភាពសំខាន់ៗប្រចាំខែឆ្នាំ២០២២

### មករា បញ្ជ្រាបការយល់ដឹងដល់សាធារណៈជន

មានភ្ញៀវចំនួន១,៣៧៨នាក់ បានមកទស្សកិច្ចមណ្ឌលទុំឌីដើម្បីស្វែងយល់ការងារអង្គការ អាហ្សេស៊ីប កម្ពុជា។

### កុម្ភៈ ការសហការធ្វើឱ្យការងារយើងប្រសើរឡើង

យើងបានចូលរួម និងរៀបចំប្រជុំជាច្រើនជាមួយបណ្តាប្រធានកម្មវិធី និងអង្គការដៃគូដើម្បីពិនិត្យលើវឌ្ឍនភាពការងារ ចែករំលែកបច្ចុប្បន្នភាព អភិវឌ្ឍផែនការបន្ត និងពង្រឹងសហប្រតិបត្តិការជាមួយបណ្តាអង្គការពាក់ព័ន្ធ។

### មិនា យើងអបអរសាទរដល់ស្ត្រីទាំងអស់

យើងបានប្រារព្ធ ទិវានារីអន្តរជាតិលើកទី១១១ ជូនបុគ្គលិកអង្គការអាហ្សេស៊ីបក្រោមវត្តមានលោកស្រីប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានីភ្នំពេញ។

### មេសា ការប្រារព្ធសង្ក្រាន្តឆ្នាំថ្មី

យើងបានប្រារព្ធសង្ក្រាន្តឆ្នាំថ្មី ជូនកុមារីដែលមិនអាចទៅលេងគ្រួសារបានដោយមូលហេតុសុវត្ថិភាព និងកុមារីដែលមិនមានកន្លែងទៅបាន ទៅកំសាន្តតាមទីវត្តអារាមនិងកន្លែងកំសាន្តផ្សេងៗតាមភូមិ។ រីឯកុមារីមានក្រុមគ្រួសារគេមកទទួលយកទៅលេងសាច់ញាតិ មិត្តភក្តិ នៅស្រុកកំណើត។

### ឧសភា ការចូលរួមរបស់កុមារីទទួលផលពីកម្មវិធី

បានរៀបចំបោះឆ្នោតប្រចាំឆ្នាំជ្រើសរើសប្រធានក្រុមដឹកនាំសម្រាប់អាណត្តិថ្មីជាតំណាងរបស់ពួកគេនៅមណ្ឌលទុំឌី។

### មិថុនា យើងអបអរសាទរដល់កុមារទាំងអស់

ក្រុមហ៊ុនHSC បានឧបត្ថម្ភការរៀបចំបណ្ណាល័យ និងប្រារព្ធទិវាសិទ្ធិកុមារអន្តរជាតិលើកទី៧៣ជូនកុមារីនៅមណ្ឌលទុំឌី

### កក្កដា ជំនាញទំនាក់ទំនងជាគន្លឹះនៃភាពជោគជ័យ

វគ្គបណ្តុះបណ្តាលកសាងសមត្ថភាពបុគ្គលិក និងនិស្សិតអាហារូបករណ៍ឧត្តមសិក្សាសកលវិទ្យាល័យ ស្តីអំពីជំនាញភាពជាអ្នកដឹកនាំ ការនិយាយសាធារណៈ និងទំនាក់ទំនង បានធ្វើឡើងតាមកម្មវិធីStructogram រយៈពេល២ថ្ងៃ ដោយគ្រូឧទ្ទេសនាមលោកស្រី Maryse Gabby ជាសមាជិកក្រុមប្រឹក្សាភិបាលមូលនិធិ Solyna។

### សីហា អភិវឌ្ឍជំនាញ ដើម្បីជំរុញគុណភាពការងារ

វគ្គបណ្តុះបណ្តាលកសាងសមត្ថភាពបុគ្គលិក និងនិស្សិតអាហារូបករណ៍ឧត្តមសិក្សាសកលវិទ្យាល័យ ស្តីអំពីការធ្វើបទបង្ហាញផ្ទាល់មាត់និងមានឯកសារ នៃជំនាញនិយាយសាធារណៈរយៈពេល២ថ្ងៃ ដោយគ្រូឧទ្ទេសនាមលោកស្រី Maryse Gabby ជាសមាជិកក្រុមប្រឹក្សាភិបាលមូលនិធិ Solyna ។

### កញ្ញា ប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ

យើងបានប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ ជូនកុមារីដែលមិនអាចទៅលេងគ្រួសារបាន ដោយមូលហេតុសុវត្ថិភាព និងកុមារីដែលមិនអាចទៅកន្លែងណាបានដោយបានធ្វើចង្ហាន់យកទៅប្រគេនព្រះសង្ឃនៅតាមវត្តអារាម ដើម្បីឧទ្ទិសកុសលជូនញាតិការទាំង៧សណ្តានដែលចែកឋានទៅបរលោកនិងបន់ស្រន់សុំសេចក្តីសុខ និងបានទៅកំសាន្តតាមភូមិ។

### តុលា អភិវឌ្ឍជំនាញ និងស្វ័យថែទាំសម្រាប់បុគ្គលិក

វគ្គបណ្តុះបណ្តាលអំពីការវាយតំលៃការងារពិគ្រោះយោបល់ និងផ្តល់ប្រឹក្សាដល់បុគ្គលិកកម្មវិធីចិត្តសាស្ត្រចំនួន៣នាក់បានធ្វើចំនួន៤វគ្គ ដោយគ្រូឧទ្ទេសនាម លោកបណ្ឌិតសាស្ត្រាចារ្យ ដើម្បីអភិវឌ្ឍជំនាញផ្តល់ប្រឹក្សា និងការអនុវត្តជាក់ស្តែង ដល់បុគ្គលិកកម្មវិធីចិត្តសាស្ត្រ ក្នុងគោលបំណងផ្តល់ជំនួយសុខភាពផ្លូវចិត្តដល់កុមារីដែលយើងធ្វើការជាមួយឱ្យកាន់តែមានគុនភាពខ្ពស់។ មានបុគ្គលិក១នាក់បានបញ្ចប់ការរៀនបើកបរ និង១នាក់ទៀតបានរៀន QuickBooks។

### វិច្ឆិកា ពិនិត្យការអនុវត្តន៍ និងអភិវឌ្ឍគម្រោងប្រចាំឆ្នាំ

សិក្ខាសាលាពិគ្រោះយោបល់ប្រចាំឆ្នាំរយៈពេល៣ថ្ងៃបានធ្វើឡើងជាមួយបណ្តាកម្មវិធីទាំងអស់ ដើម្បីវាយតម្លៃលទ្ធផលសម្រេចបាន បញ្ហាប្រឈមឆ្នាំ២០២២របស់កម្មវិធីនីមួយ ៗ លើកផែនការសកម្មភាព និងគម្រោងថវិកាឆ្នាំ២០២៣។

### ធ្នូ បានរៀបចំប្រជុំក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ

បានប្រជុំក្រុមប្រឹក្សាភិបាលតាមអនឡាញ មានសមាជិកពីប្រទេសកម្ពុជា អូស្ត្រាលី អាមេរិក និងស្វីស ដើម្បីរបាយការណ៍ជូនអំពីលទ្ធផលសម្រេចបានក្នុងឆ្នាំ២០២២ ឆ្លងផែនការកម្មភាព និងគម្រោងថវិកាឆ្នាំ២០២៣។

# ករណីជោគជ័យរបស់យុវនារី ទទួលផលពីកម្មវិធីយើង

**សុជាតា** ឥឡូវនេះអាយុ២៣ឆ្នាំ។ នាងបានត្រូវបានបញ្ជូនមក អាហ្វេស៊ីប នៅឆ្នាំ២០១១ តាំងពីនាងអាយុ១១ឆ្នាំ។ យើងបានមាហរណកម្មនាងទៅ គ្រួសារវិញ នៅក្នុងទីក្រុងភ្នំពេញ ដោយបានបន្តឧបត្ថម្ភអាហារូបករណ៍ក្រោមឧត្តមសិក្សាដល់នាង។



នាងបានប្រឡងជាប់មធ្យមសិក្សាទុតិយភូមិនៅឆ្នាំ២០១៦ ហើយបានបន្តអាហារូបករណ៍ឧត្តមសិក្សានៅសកលវិទ្យាល័យ ប៉ុន្តែដោយសារស្ថានភាពគ្រួសារនាងបានព្យួរការសិក្សារយៈពេល២ឆ្នាំ។ នាងបានសិក្សាជំនាញគ្រប់គ្រងនៅសកលវិទ្យាល័យជាតិគ្រប់គ្រង (NUM) រយៈពេល៤ឆ្នាំ ហើយបានបញ្ចប់ការសិក្សាបរញ្ញាបត្រផ្នែកគ្រប់គ្រងដោយជោគជ័យ នៅខែមករា ឆ្នាំ២០២២។

នាងបានហាត់ការនៅអាហ្វេស៊ីបកម្ពុជា នៅដើមឆ្នាំ២០២២ រយៈ៤ខែ។ យើងធ្វើការលើកកម្ពស់ជនរងគ្រោះឱ្យក្លាយជាអតីតជនរងគ្រោះ ហើយលើកកម្ពស់អតីតជនរងគ្រោះ ឱ្យទៅជាផ្នែកមួយនៃដំណោះស្រាយ។ នាងក៏ដូចជាយុវតីដ៏ទៃទៀតដែរ ដែលបានបញ្ចប់ការសិក្សា ឥឡូវបានបម្រើការងារ ជាបុគ្គលិកពេញម៉ោង ផ្នែកហិរញ្ញវត្ថុ នៅក្នុងឆ្នាំ២០២២នេះ។ យើងបានសមាហរណកម្មនាងជាមួយការងារ នៅខែវិច្ឆិកា ឆ្នាំ២០២២ បន្ទាប់ពីនាងត្រូវបានវាយតម្លៃ និងឆ្លងផុតរយៈពេលនៃការសាកល្បងការងាររបស់សមាជិកនៃគណៈគ្រប់គ្រងអង្គការអាហ្វេស៊ីបកម្ពុជា។

**សុភ័ក្រ** ឥឡូវអាយុ២២ឆ្នាំ ឪពុកម្តាយនាងបានលែងលះគ្នា តាំងពីនាងអាយុ១៥ថ្ងៃម្លេះ។នាងបានរស់នៅជាមួយម្តាយជាស្ត្រីមេម៉ាយនិង ជីតាចាស់ជរា។ គ្រួសារនាងក្រខ្លាំងណាស់ នាងមកពីខេត្តសៀមរាប។ មន្ទីរសង្គមកិច្ចបានបញ្ជូន នាងមកមណ្ឌលអាហ្វេស៊ីបនៅឆ្នាំ២០១៤ ពេលនោះនាងមានអាយុ១៤ឆ្នាំ។ នាងជាកុមារីរងគ្រោះដោយការរំលោភបំពាន។



នាងបានប្រឡងជាប់មធ្យមសិក្សាទុតិយភូមិនៅឆ្នាំ២០១៧ ហើយបានបន្តអាហារូបករណ៍ឧត្តមសិក្សា ផ្នែកគ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច។ នាងចំណាយពេល៤ឆ្នាំ សិក្សានៅសកលវិទ្យាល័យ និងបានបញ្ចប់ការសិក្សាបរញ្ញាបត្រលើជំនាញនាងជ្រើសរើសដោយជោគជ័យនៅខែឧសភាឆ្នាំ២០២២។

បច្ចុប្បន្ន នាងបម្រើការជាបុគ្គលិកពេញម៉ោង ផ្នែកលក់ និងបដិសណ្ឋារកិច្ចនៅក្រុមហ៊ុនទេសចរណ៍មួយនៅទីក្រុងភ្នំពេញ ទទួលបានប្រាក់បៀវត្សសមរម្យ។ យើងបានសមាហរណកម្មនាងជាមួយការងារ នៅខែវិច្ឆិកា ឆ្នាំ២០២២ បន្ទាប់ពីនាងត្រូវបានវាយតម្លៃ និងឆ្លងផុតរយៈពេលការសាកល្បងការងាររបស់ក្រុមហ៊ុន ដោយការប្រើប្រាស់ជំនាញនាងបានសិក្សានៅសកលវិទ្យាល័យជាអាជីព ។ ការប្រើប្រាស់ជំនាញនាងបានសិក្សា អាចជួយនាងបានឆ្លងផុតពីបន្ទាត់ក្រីក្រ តាមរយៈបានប្រាក់ចំណូលទៀងទាត់ ផ្គត់ផ្គង់ខ្លួននាង និងក្រុមគ្រួសារនៅឯស្រុកកំណើត។

**វណ្ណាត** បច្ចុប្បន្នអាយុ២០ឆ្នាំ មកពីខេត្តសៀមរាប ជាកូនស្រីពៅ មានបងប្អូន៥នាក់ ឪពុកជាកម្មករសំណង់ ម្តាយជាស្ត្រីមេផ្ទះ។ នាងត្រូវបានបញ្ជូនមកអាហ្វេស៊ីបអាយុ១៤ឆ្នាំ នៅឆ្នាំ២០១៦ ក្នុងករណី នាងមានហានីភ័យខ្ពស់ក្នុងគ្រួសារ ព្រោះថាបងស្រីនាង ក៏បានបញ្ជូនមកមណ្ឌល អាហ្វេស៊ីប កម្ពុជាដែរ ដោយសារនាង ជាជនរងគ្រោះដោយការរំលោភបំពាន។ នៅថ្ងៃអានាគតនាង ចង់ធ្វើជាមេធាវី។



នៅខែធ្នូ ឆ្នាំ២០២០ នាងបានប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ ហើយបានបន្តអាហារូបករណ៍ឧត្តមសិក្សា។ បច្ចុប្បន្ន នាងកំពុងសិក្សា បរិញ្ញាបត្រផ្នែកច្បាប់ ឆ្នាំទី៣ នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ នាងចង់ធ្វើជាមេធាវី ជួយជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះ ធ្វើជាតំណាង ស្វែងរកយុត្តិធម៌ឱ្យជនរងគ្រោះ នៅចំពោះមុខច្បាប់ និងឱ្យជនប្រព្រឹត្តខុសទទួលខុសត្រូវបទល្មើសដែលពួកគេបានប្រព្រឹត្តចំពោះមុខច្បាប់។

នៅខែសីហា ឆ្នាំ២០២២ នាងបានប្តូរទៅសិក្សាពេលយប់ បច្ចុប្បន្ននាងកំពុងបម្រើការ ជាបុគ្គលិកពេញម៉ោង ផ្នែករដ្ឋបាលនៅបើហ្គឺឃីង ក្រុមហ៊ុនHSC ក្នុងគោលបំណងស្វែងរកបទពិសោធន៍ និងប្រាក់ចំណូលផ្គត់ផ្គង់ក្រុមគ្រួសារ។

**រីយ៉ា** បច្ចុប្បន្នអាយុ២២ឆ្នាំ នាងត្រូវបានបញ្ជូនមកមណ្ឌល អាហ្វេស៊ីប នៅខែវិច្ឆិកា ឆ្នាំ២០១៥ ពេលនោះនាងអាយុ១៦ឆ្នាំ។ បន្ទាប់ពីនាងបានស្តារនីតិសម្បទា យើងបានសមាហរណកម្មនាងទៅគ្រួសារវិញ ដោយបានបន្តឧបត្ថម្ភ អាហារូបករណ៍ក្រោមឧត្តមសិក្សា ស្នាក់នៅក្រៅមណ្ឌល ជាមួយក្រុមគ្រួសារ នៅខែកញ្ញា ឆ្នាំ២០១៨ ។



ដោយភាពក្រីក្រ ម្តាយនាងមិនអាចឱ្យនាងបន្តការសិក្សាបាន នាងក៏សម្រេចចិត្តបោះបង់ការសិក្សា នៅឆ្នាំ២០២០។ បន្ទាប់មក អាហ្វេស៊ីប កម្ពុជា បានបន្តឧបត្ថម្ភអាហារូបករណ៍ជំនាញវិជ្ជាជីវៈផ្នែកធ្វើភេសជ្ជៈដល់នាងតាមបំណងប្រាថ្នារបស់នាង។ នាងបានបញ្ចប់ការបណ្តុះបណ្តាលផ្នែកធ្វើភេសជ្ជៈដោយជោគជ័យ នៅខែមករា ឆ្នាំ២០២២ នៅសាលាម្ហូបអាហារមួយកន្លែង នៅក្រុងភ្នំពេញ។ ក្រោយពីបញ្ចប់ការបណ្តុះបណ្តាល នាងបានហាត់ការជាអ្នកធ្វើភេសជ្ជៈនៅហាងកាហ្វេមួយ ប៉ុន្តែរយៈពេលពីរបីខែក្រោយមក ហាងនោះបានបិទដើម្បីជួសជុលកែរលំអរ។ បច្ចុប្បន្ននាងបម្រើការជាបុគ្គលិកពេញម៉ោងនៅហាងកាហ្វេមួយកន្លែងក្បែរផ្ទះសាច់ញាតិរបស់នាងនៅខេត្តកំពង់ស្ពឺ។

យើងបានសមាហរណកម្មនាងជាមួយការងារ នៅខែសីហា ឆ្នាំ២០២២ បន្ទាប់ពីនាងបានឆ្លងផុតរយៈពេលការសាកល្បងការងារ ដោយប្រើជំនាញដែលនាងមាន។ ឥឡូវនាងអាចយកប្រាក់ចំណូលមួយផ្នែកជួយម្តាយនាង។

## របាយការណ៍សង្ខេប

ស្ទើរគ្រប់សុចនករំពឹងទុកកម្មវិធីនីមួយៗ ដែលយើងបានដាក់ចេញ អនុវត្តសម្រេចបានលទ្ធផលល្អប្រសើរ ថ្វីបើយើងជួបបញ្ហាប្រឈមនៃការរីករាលដាលមេរោគកូវីដ-១៩ នៅដើមឆ្នាំក៏ដោយ។ មានកម្មវិធីខ្លះសម្រេចបានលទ្ធផល លើសពីការរំពឹងទុកនៃផែនការរបស់យើង ដូចជាផែនការទទួលយកកុមារីរងគ្រោះចូលមណ្ឌលចំនួន២៥នាក់ ប៉ុន្តែជាក់ស្តែងយើងបានទទួលកុមារីរងគ្រោះចូលស្នាក់នៅក្នុងមណ្ឌលរហូតដល់៣៧នាក់ ក្នុងរយៈពេល១២ខែ។

កុមារីចំនួន១០៩នាក់បានទទួលការស្នាក់នៅដោយសុវត្ថិភាព អាហារូបត្ថម្ភ ការថែទាំសុខភាព ការពិគ្រោះយោបល់ចិត្តសង្គម ជំនួយនីតិកម្ម ការអប់រំ និងបណ្តុះបណ្តាលខណៈកំពុងស្នាក់នៅក្នុងមណ្ឌលទុំឌី។

យុវនារី-កុមារីចំនួន១៨៤នាក់ បានទទួលអាហារូបករណ៍ក្រោមឧត្តមសិក្សា ឧត្តមសិក្សា និង ជំនាញវិជ្ជាជីវៈដូចក្នុងតារាងបង្ហាញជូនខាងក្រោមនេះ៖

| ស្ថិតិសង្ខេបកុមារីទទួលការថែទាំ&ឧបត្ថម្ភ | ២០២៣ | | ចុង២០២២ - បន្ត២០១២៣ | |
|---|---|---|---|---|
| | សរុប | សម្គាល់ | សរុប | សម្គាល់ |
| កុមារីទទួលការថែទាំក្នុងមណ្ឌល | ១០៩ | (៧២នាក់ចុងគ្រា២០២១ និង ៣៧នាក់ចូលថ្មី | ៦២ | (៤៧នាក់ចេញពីមណ្ឌល) |
| សិស្សអាហារូបករណ៍ក្រោមឧត្តមសិក្សា(ក្នុងម.ណ) | ៨២ | (៥៦នាក់ចុងគ្រា២០២១ និង២៦នាក់ចូលរៀនថ្មី) | ៥៥ | (២៧នាក់អាហារូបករណ៍ក្រោមឧត្តមសិក្សា និង២នាក់ជាប់មធ្យមសិក្សាទុតិយភូមិ) |
| សិស្សអាហារូបករណ៍ជំនាញវិជ្ជាជីវៈ | ១៦ | (១០នាក់ចុងគ្រា២០២១ ៦នាក់ចូលរៀនថ្មី) | ៥ | (៦នាក់បញ្ចប់ការសិក្សាជំនាញ និង៥នាក់បោះបង់) |
| សិស្សអាហារូបករណ៍ក្រោមឧត្តមសិក្សា(ក្រៅម.ណ) | ៧១ | (៤៥នាក់ចុងគ្រា២០២១ និង២៦នាក់ចូលរៀនថ្មី) | ៦០ | (៦នាក់ជាប់មធ្យមសិក្សាទុតិយភូមិនិង៥នាក់បោះបង់) |
| និស្សិតអាហារូបករណ៍ឧត្តមសិក្សាសកលវិទ្យាល័យ | ១៥ | (១២នាក់ចុងគ្រា២០២១ និង៣នាក់ចូលរៀនថ្មី) | ១០ | (៤នាក់បានបញ្ចប់ការសិក្សា និង១នាក់បោះបង់) |
| សមាហរណកម្មជាមួយការងារ និងមុខរបរ | ១៧ | | ១៧ | |
| សមាជិកបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ | ៣៧ | (១៦នាក់ចុងគ្រា២០២១ និង២១នាក់សមាជិកថ្មី) | ៣៧ | |
| ករណីសមាហរណកម្មស្ថិតក្រោមការតាមដានបន្ត | ១៦០ | (១១៩នាក់ចុងគ្រា២០២១ និង៤១នាក់ថ្មី) | ១៦០ | |
| សរុប | ៥០៧ | | ៤០៦ | |

ផ្អែកលើការវិភាគស្ថិតិផ្ទៃក្នុងអំពីបញ្ហារបស់កុមារីរងគ្រោះដែលយើងទទួលចូលមណ្ឌល បានបង្ហាញថាតួលេខកុមារីរងគ្រោះដោយការរំលោភសេពសន្ថវៈបានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ កុមារីរងគ្រោះដោយការរំលោភសេពសន្ថវៈក្មេងជាងគេនៅកន្លែងថែទាំរបស់យើងគឺមានអាយុ១៣ខែ។



# អំពីសកម្មភាពការងារយើង

កម្មវិធីស្នូល អង្គការ អាហ្វេស៊ីប កម្ពុជា គឺស្តារនីតិសម្បទា អប់រំនិងបណ្តុះបណ្តាល លើកកម្ពស់សេដ្ឋកិច្ច (សមាហរណកម្ម) និងបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ។

## ស្តារនីតិសម្បទា

### មណ្ឌល ទុំ ឌី

ជាកន្លែងព្យាបាលមួយ តាមរយៈការផ្តល់កន្លែងស្នាក់នៅមានសុវត្ថិភាព អាហារ១ថ្ងៃ៣ពេល ការថែទាំ អាហារូបត្ថម្ភ ការពិនិត្យព្យាបាលសុខភាព ការពិគ្រោះនិងព្យាបាលសុខភាពផ្លូវចិត្ត និងជំនួយផ្នែកច្បាប់ ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍន៍សុខមាលភាពផ្លូវកាយ និងផ្លូវចិត្ត ដល់កុមារីរងគ្រោះដែលយើងធ្វើការជាមួយ។

### *ហេតុអ្វីបានជាយើងធ្វើការងារនេះ?*

មណ្ឌលទុំឌីជាដំណាក់កាលដំបូង ក្នុងការធ្វើឱ្យកុមារីរងគ្រោះ និងងាយរងគ្រោះមានស្ថេរភាព ផុតពីទុក្ខកង្វល់ដែលពួកគាត់បានជួបប្រទះ ជាទូទៅពួកគាត់អាចទទួលបានបរិយាកាសសុវត្ថិភាព ជួបជាមួយបុគ្គលិកថែទាំ គ្រូពេទ្យ ចិត្តសាស្ត្រ បុគ្គលិកគាំពារផ្នែកច្បាប់ សមាជិកបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ កសាងទំនុកចិត្ត និងទំនាក់ទំនង។

### *តើធ្វើឱ្យមានភាពខុសគ្នាអ្វីខ្លះ?*

នៅឆ្នាំ២០២២ យើងបានផ្តល់ជម្រកសុវត្ថិភាព អាហារូបត្ថម្ភ សម្លៀកបំពាក់ និងគ្រឿងឧបភោគ-បរិភោគ ដល់កុមារីជាច្រើននាក់ ដែលត្រូវបានរងគ្រោះ និងងាយរងគ្រោះដោយអំពើហិង្សាផ្លូវភេទ ជួញដូរ រំលោភបំពាន ទាសភាព និងកេងប្រវ័ញ្ចផ្លូវភេទ នៅក្នុងមណ្ឌលទុំឌី។

### *អ្វីយើងបាននិយាយថាយើងនឹងធ្វើ*

យើងបាននិយាយថា យើងនឹងផ្តល់ការថែទាំគ្រប់ជ្រុងជ្រោយដល់កុមារីចំនួន៨៥នាក់ នៅមណ្ឌលទុំឌី។

### *លទ្ធផលយើងសម្រេចបាន*

កុមារីចំនួន១០៩នាក់ បានទទួលការថែទាំគ្រប់ជ្រុងជ្រោយ ជម្រកសុវត្ថិភាព អាហារូបត្ថម្ភនៅមណ្ឌលទុំឌី។ លទ្ធផលសម្រេចបានលើសផែនការ។

### *ប្រភពបញ្ជូនជនរងគ្រោះ*

អាហ្វេស៊ីប កម្ពុជា បានសាងបណ្តាញការងារជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(មន្ទីរ ស.អ.យ) អាជ្ញាធរមូលដ្ឋាន និងបណ្តាភាគីពាក់ព័ន្ធនៅតាមបណ្តាខេត្ត ជាប្រភពបញ្ជូនកុមារីរងគ្រោះមកទទួលសេវាស្តារនីតិសម្បទានៅមណ្ឌលយើង។

រៀបចំអាហារ



ផ្តល់អាហារ



ធ្វើលំហាត់ប្រាណ



### ស្ថិតយុវនារី-កុមារីចេញពីមណ្ឌល

- យុវនារី៥នាក់ បានស្តារឡើង ទទួលអាហារូបករណ៍ជំនាញវិជ្ជាជីវៈ ស្នាក់នៅក្រៅមណ្ឌល។
- យុវនារី២នាក់ បានប្រឡងមធ្យមសិក្សាទុតិយភូមិ បន្តអាហារូបករណ៍ឧត្តមសិក្សាសកលវិទ្យាល័យ។
- កុមារី២៥នាក់ បានស្តារឡើង ទទួលអាហារូបករណ៍ក្រោមឧត្តមសិក្សានៅក្រៅមណ្ឌលជាមួយគ្រួសារ។
- កុមារី១៥នាក់ បានស្តារឡើង យើងបានបញ្ជូនពួកគាត់ទៅរស់នៅជាមួយក្រុមគ្រួសារវិញ។

### ស្ថិតយុវនារី-កុមារីទទួលការថែទាំបន្ត

- កុមារី៦២នាក់ បន្តទទួលការថែទាំពេញលេញ នៅក្នុងមណ្ឌលទុំ ឌី នៅចុងគ្រា ខែធ្នូ ឆ្នាំ២០២២។

## សុខភាព

ជនរងគ្រោះដោយការជួញដូរ រំលោភសេពសន្ថវៈ រំលោភបំពានផ្លូវភេទ ឬការកេងប្រវ័ញ្ចផ្លូវភេទ តែងតែជាប់នូវស្លាកស្នាមវិប្បដិសារី និងការមាក់ងាយពីមជ្ឈដ្ឋានជុំវិញ ដែលជាកត្តាធ្វើឱ្យប៉ះពាល់ដល់ការអភិវឌ្ឍផ្លូវកាយ និងផ្លូវចិត្ត។ កុមារីទទួលបានការពិនិត្យ និងវាយតម្លៃសុខភាពទូទៅ នៅពេលពួកគាត់មកដល់មណ្ឌលភ្លាម និងផ្តល់ការពិនិត្យព្យាបាលបន្ត តាមតម្រូវការជាក់ស្តែងពីវេជ្ជបណ្ឌិតរបស់យើង។

### អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថា យើងនឹងផ្តល់ការថែទាំសុខភាព ១០០%ដល់កុមារីចូលថ្មីចំនួន២៥នាក់ នៅមណ្ឌលទុំ ឌី និងផ្តល់ការពិនិត្យ ព្យាបាលបន្ត ដល់កុមារីចំនួន៨០នាក់ តាមតម្រូវការជាក់ស្តែងរបស់ករណីនីមួយៗ។

### លទ្ធផលយើងសម្រេចបាន

១០០%នៃកុមារីចូលថ្មីចំនួន៣៧នាក់ នៅមណ្ឌលទុំឌី បានទទួលការពិនិត្យ វាយតម្លៃ និងព្យាបាលសុខភាព លើរោគសញ្ញាសំខាន់ៗ ដូចជា បាក់តេរីទ្វារមាស រលាកមាត់ស្បូន ដង្កូវស៊ីធ្មេញ និងរាគ។ កុមារីចំនួន១២៤នាក់បានទទួលការពិនិត្យ និងព្យាបាលបន្តចំនួន ១១៤១ដង តាមតម្រូវការជាក់ស្តែង លើរោគសញ្ញាគ្រុនផ្តាសាយ រលាកបំពង់ក ផ្តាសាយធំ ពុលអាហារ និងរាគ នៅក្នុងឆ្នាំ២០២២។ កុមារទទួលបានការថែទាំសុខភាពលើសពីផែនការរំពឹងទុក។

- កុមារីចំនួន១០០នាក់ បានទទួលការចាក់វ៉ាក់សាំងជាតិ៦មុខ ដើម្បីបង្ការជំងឺមេរោគមហារីកមាត់ស្បូន (HPV) តេតាណូស កូវីដ-១៩ ផលលំបាកនៃការក្តៅខ្លួន ផ្តាសាយ និងថ្លើមប្រភេទបេ។
- កុមារីចំនួន៥៩នាក់ បានទទួលការពិនិត្យ ព្យាបាលសុខភាពមាត់ធ្មេញ ដោយសហការជាមួយអង្គការគ្រួសារ ពិភពលោក កម្ពុជា។
- កុមារីចំនួន២៤នាក់ បានទទួលការពិនិត្យ ព្យាបាល ថែទាំភ្នែក ត្រចៀក ច្រមុះ និងបំពង់ក (EENT) ដោយសហការជាមួយមជ្ឈមណ្ឌលវះកាត់កុមារ។
- កុមារីចំនួន៣០នាក់ បានធ្វើតេស្តឈាម CBC glycaemia និង Ag-Anti-HBS កុមារីចំនួន១៨នាក់បានធ្វើតេស្តហ៊ីវ (HIV) ដោយស្ម័គ្រចិត្ត។
- កុមារីចំនួន១៣នាក់ បានធ្វើតេស្ត (VIA) និងចាក់វ៉ាក់សាំងការពារបង្ការមហារីកមាត់ស្បូន។
- កុមារីចំនួន១៤ករណី បានទទួលថ្នាំព្យាបាលជំងឺគាំរមកំហែងអាយុជីវិតធ្ងន់ធ្ងរ។
- កុមារីចំនួន៥នាក់ បានទទួលថ្នាំព្យាបាលជំងឺថ្លើមប្រភេទ។

- កុមារីចំនួន៧៩នាក់ បានទទួលការអប់រំសុខភាពបឋម ស្តីពីអនាម័យខ្លួនប្រាណ ការសេពគ្រឿងស្រវឹង និងជំងឺគ្រុនឈាម។

ការពិនិត្យដោយម៉ាស៊ីនអេកូ



ការពិនិត្យសុខភាពទូទៅ



ព្យាបាលសុខភាពមាត់ធ្មេញ



## សុខភាពផ្លូវចិត្ត

យើងដឹងហើយថា ឥទ្ធិពលនៃផលប៉ះបាល់ផ្នែកសុខភាពផ្លូវចិត្ត គឺការបាក់ទឹកចិត្ត និងការផ្តាច់ទំនាក់ទំនង ដូច្នេះកម្មវិធីស្តារនីតិសម្បទា យើងផ្តោតលើការលើកទឹកចិត្ត និងការបង្កើតទំនាក់ទំនងថ្មីៗ ដល់កុមារីដែលយើងធ្វើជាមួយទាំងនៅក្នុងមណ្ឌល និងនៅតាមសហគមន៍។ ពេលពួកគាត់មកដល់មណ្ឌលភ្លាម បានទទួលការវាយតំលៃសុខភាពផ្លូវចិត្ត ការព្យាបាលបន្ទាន់ និងការតាមដានសុខភាពជាបន្តបន្ទាប់តាមតម្រូវការជាក់ស្តែងពីបុគ្គលិកចិត្តវិទ្យារបស់យើង។

### អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថា១០០%នៃកុមារីរងគ្រោះចូលថ្មីចំនួន២៥នាក់ នឹងទទួលបានការវាយតំលៃសុខភាពផ្លូវចិត្ត ពេលពួកគាត់ចូលមកដល់មណ្ឌលទុំឌី និងកុមារីចំនួន៨៥នាក់នឹងទទួលបានការតាមដាន និងព្យាបាលសុខភាពផ្លូវចិត្តតាមតម្រូវការជាក់ស្តែង។

### លទ្ធផលយើងសម្រេចបាន

៩៧%នៃចំនួនកុមារីរងគ្រោះចូលថ្មីចំនួន៣៦នាក់ (នៃ៣៧) នៅមណ្ឌលទុំឌី បានទទួលការវាយតម្លៃសុខភាពផ្លូវចិត្តទូទៅ ដែលមានរោគសញ្ញាហៀរទឹកភ្នែក ព្រួយបារម្ភ សុបិន្តអាក្រក់ ខ្វល់ខ្វាយ និងនឹកផ្ទះ។ កុមារីចំនួន១៤២នាក់បានទទួលការតាមដាននិងព្យាបាលសុខភាពផ្លូវចិត្តតាមតម្រូវការជាក់ស្តែងដូចជា ព្រួយបារម្ភ ខ្វល់ខ្វាយ ហៀរទឹកភ្នែក និងអាកប្បកិរិយាកោងកាច។ ចំនួនកុមារីទទួលបានការពិគ្រោះយោបល់ និងព្យាបាលសុខភាពផ្លូវចិត្ត លើសផែនការយើងរំពឹងទុក។

- កុមារីចំនួន៥៨នាក់ បានទទួលការព្យាបាលសុខភាពផ្លូវចិត្ត តាមបែបសិល្បៈចំនួន២៣វគ្គ។
- កុមារីចំនួន៨៥នាក់ បានទទួលវគ្គបណ្តុះបណ្តាលការជួយខ្លួនឯងបានចំនួន២៤វគ្គ អំពីប្រធានបទផ្សេងៗដូចជា ការឆ្លុះបញ្ចាំងខ្លួនឯង ការយល់ដឹងពីខ្លួនឯង ការគ្រប់គ្រងកំហឹង ការឱ្យតំលៃជឿជាក់លើខ្លួនឯង នីតិវិធីតុលាការ និងការបង្កើតគោលដៅ។

- កុមារីចំនួន៧៥នាក់ បានទទួលវគ្គបណ្តុះបណ្តាលអំពីការថែទាំសុខភាពផ្លូវចិត្តបឋម និងការអប់រំបង្ការបានចំនួន១០វគ្គ។
- កុមារីចំនួន៩៧នាក់ បានហ្វឹកហ្វឺន និងអនុវត្តយោគៈជាប្រចាំនៅចុងសប្តាហ៍បាន៦៣វគ្គ នៅមណ្ឌលទុំឌី។
- កុមារីចំនួន២៧នាក់ បានទទួលការពិគ្រោះយោបល់ចិត្តសង្គមនៅមុនអំឡុង និងក្រោយពេល ចូលធ្វើយបំភ្លឺ និងចូលរួមសវនការជំរះក្តីនៅតុលាការ។
- កុមារីចំនួន២០នាក់ បានទទួលការពិគ្រោះយោបល់ចិត្តសង្គមនៅមុន អំឡុង និងក្រោយពេលទទួលចូលមណ្ឌលទុំឌី ។
- គ្រួសារកុមារីចំនួន២៨គ្រួសារ បានទទួលការពិគ្រោះយោបល់ ក្នុងអំឡុងពេលដំណើរការនីតិវិធីច្បាប់ នៅដំណាក់កាលសាកសួរនិងសវនាការជំរះក្តីនៅតុលាការ។
- បានទិញកម្រាលសម្រាប់ហាត់យោគៈចំនួន១០០កម្រាល សំភារកីឡា និងសំភារផ្សេងៗ សម្រាប់តុបតែងលម្អបន្ទប់ហាត់យោគៈ និងពិគ្រោះយោបល់។

សកម្មភាពប្រឹក្សាយោបល់



សកម្មភាពវគ្គក្រុមជួយខ្លួនឯង



សកម្មភាពបតិបត្តិសមាធិ



## ជំនួយនីតិកម្ម

បុគ្គលិកផ្នែកនីតិកម្មធានាថាគ្រប់ជនរងគ្រោះទាំងអស់ ដែលយើងធ្វើការជាមួយ ហើយពាក់ព័ន្ធនីតិវិធីច្បាប់ យើងផ្តល់ជំនួយផ្នែកច្បាប់ និងជាតំណាងតាមនីតិវិធីច្បាប់ ដោយធ្វើការសហការជិតស្និតជាមួយបណ្តាអង្គការ-ស្ថាប័នដៃគូផ្សេងៗ រៀបចំឯកសារផ្នែកច្បាប់ ដើម្បីឱ្យជនសង្ស័យប្រឈមមុខចំពោះយុត្តិធម៌ និងធានាឱ្យបានថាជនរងគ្រោះទទួលបានការយកចិត្តទុកដាក់ដោយស្មើភាពចំពោះមុខច្បាប់ ។

### អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាកុមារីចំនួន៥១នាក់ ដែលពាក់ព័ន្ធនីតិវិធីច្បាប់ នឹងទទួលបានជំនួយផ្នែកច្បាប់ តាមនីតិវិធី។ ក្នុងនោះមាន២៦នាក់ ជាករណីចុងគ្រាឆ្នាំ២០២១ និង២៥នាក់ ជាករណីថ្មីពាក់ព័ន្ធច្បាប់ក្នុងឆ្នាំ២០២២។

### លទ្ធផលយើងសម្រេចបាន

កុមារីចំនួន៦២នាក់ បានទទួលជំនួយផ្នែកច្បាប់តាមនីតិវិធី។ ក្នុងនោះ២៦នាក់ ជាករណីចុងគ្រាឆ្នាំ២០២១ និង៣៦នាក់ ជាករណីថ្មីពាក់ព័ន្ធនីតិវិធីច្បាប់ក្នុងឆ្នាំ២០២២ យើងសម្រេចលទ្ធផលលើសផែនការ។

- ជនសង្ស័យចំនួន៤៥នាក់ ត្រូវបានចាប់ឃុំខ្លួនឱ្យទទួលខុសត្រូវចំពោះមុខច្បាប់។ ក្នុងនោះ១៦នាក់ជាករណីចុងគ្រាឆ្នាំ២០២១ និង២៩នាក់ជាករណីថ្មីត្រូវប៉ូលីសចាប់ឃុំខ្លួនក្នុងឆ្នាំ២០២២។
- យើងបានស្នើសុំមេធាវីចំនួន៣២នាក់ ពីបណ្តាអង្គការ-ស្ថាប័នដៃគូ និងក្រុមមេធាវីស្ម័គ្រចិត្ត**សម្តេចតេជោ ហ៊ុន សែន** ដើម្បីការពារក្តី និងជាតំណាងជនរងគ្រោះតាមនីតិវិធីនៅតុលាការ។
- កុមារីចំនួន៣០នាក់ បានទទួលការធ្វើកោសល្យវិច្ឆ័យ ជាភស្តុតាងប្រឆាំងនិងជនល្មើសចំពោះមុខច្បាប់នៅតុលាការ។
- កុមារី៣០នាក់ បានចូលឆ្លើយបំភ្លឺ និងកុមារីចំនួន១៧នាក់ បានចូលរួមសវនាការជំរះក្តីនៅតុលាការ។ ជនល្មើសចំនួន១៥នាក់ត្រូវបានតុលាការកាត់ទោសឱ្យជាប់ព័ន្ធនាការ កំរិតទោសទាប និងខ្ពស់បំផុត ជាប់ពន្ធនាគារពី៣ដល់១៥ឆ្នាំ។ បង្គាប់សំណងរដ្ឋប្បវេណី៤ដល់៨០លានរៀល ប៉ុន្តែជនរងគ្រោះមិនដែលទទួលបានសំណងរដ្ឋប្បវេណីទេ។
- កុមារីចំនួន៥៨នាក់ បានទទួលការតាមដានជាមួយមេធាវី អំពីវឌ្ឍនភាពលើករណីរបស់ពួកគាត់ដែលពាក់ព័ន្ធនីតិវិធីច្បាប់បានចំនួន៣១៦ដង ភាគច្រើនធ្វើការតាមដានតាមទូរស័ព្ទ ។

សកម្មភាពនីតិវិធីប្រគល់-ទទួល



សកម្មភាពដៃគូបញ្ជូនកុមារីរងគ្រោះ



សកម្មភាពចូលរួមសវនការនៅតុលាការ




## កម្មវិធីអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ

យើងធានាឱ្យបានថា កុមារីទទួលបានការអប់រំ និងជំនាញវិជ្ជាជីវៈជាក់លាក់មួយ ដែលស្ថិតក្នុងបរិស្ថានសុវត្ថិភាព។ អង្គការអាហ្វេស៊ីបផ្តល់ (១) អាហារូបករណ៍អប់រំក្រោមឧត្តមសិក្សាដល់កុមារីស្នាក់នៅក្នុងមណ្ឌលទុំឌី (២) អាហារូបករណ៍ដល់កុមារីបានស្តារសម្បទា ដែលស្នាក់នៅក្រៅមណ្ឌលជាមួយក្រុមគ្រួសារសាច់ញាតិរបស់ពួកគាត់(៣) អាហារូបករណ៍ឧត្តមសិក្សាសកលវិទ្យាល័យ និង(៤)អាហារូបករណ៍ជំនាញវិជ្ជាជីវៈ។

### *ហេតុអ្វីបានជាយើងធ្វើការងារនេះ?*

ទិសដៅចំបងរបស់យើងគឺធ្វើឱ្យអ្នកទទួលផល សម្រេចបាននូវស្វ័យភាព ពិសេសគឺឯករាជ្យភាពហិរញ្ញវត្ថុ តាមរយៈការផ្តល់ឱកាសឱ្យពួកគាត់មានការងារធ្វើ ឬបង្កើតមុខរបរផ្ទាល់ខ្លួនក្រោយពេលបញ្ចប់ការសិក្សា។

## តើធ្វើឱ្យមានភាពខុសគ្នាអ្វីខ្លះ?

កុមារីចំនួន១៨៤នាក់ បានទទួលអាហារូបករណ៍ក្រោមឧត្តមសិក្សាខណៈស្នាក់នៅក្នុងមណ្ឌល អាហារូបករណ៍បន្តការសិក្សាស្នាក់នៅក្រៅមណ្ឌលជាមួយក្រុមគ្រួសារសាច់ញាតិពួកគាត់បន្ទាប់ពីបានស្តារ អាហារូបករណ៍ឧត្តមសិក្សាសកលវិទ្យាល័យ និងអាហារូបករណ៍ជំនាញវិជ្ជាជីវៈ។

## អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្នុងមណ្ឌល

### អ្វីយើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាកុមារីចំនួន៧៥នាក់ នឹងទទួលបានអាហារូបករណ៍ក្រោមឧត្តមសិក្សាខណៈស្នាក់នៅក្នុងមណ្ឌលទុំឌី។

### លទ្ធផលយើងសម្រេចបាន

កុមារីចំនួន៨២នាក់បានទទួលអាហារូបករណ៍ក្រោមឧត្តមសិក្សាចាប់ពីថ្នាក់មត្តេយ្យដល់វិទ្យាល័យខណៈស្នាក់នៅក្នុងមណ្ឌលទុំឌី។

- យុវតីចំនួន២នាក់ បានប្រឡងមធ្យមសិក្សាទុតិយភូមិ (ធ្លាក់១នាក់) ហើយបន្តអាហារូបករណ៍ឧត្តមសិក្សាសកលវិទ្យាល័យ។
- កុមារីចំនួន២៥នាក់បានសមាហរណកម្ម ទៅគ្រួសារ(៨នាក់) អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌល(១៥នាក់) និងផ្សេងៗ(២នាក់)។
- កុមារីចំនួន៥៥នាក់ កំពុងបន្តអាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្នុងមណ្ឌល។







## អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌល

### យើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាកុមារី៦១នាក់ នឹងបានទទួលអាហារូបករណ៍ស្នាក់នៅក្រៅមណ្ឌល ជាមួយក្រុមគ្រួសារពួកគាត់ បន្ទាប់ពីបានស្តារ។

### លទ្ធផលយើងសម្រេចបាន

កុមារីចំនួន៧១នាក់បានទទួលការឧបត្ថម្ភអាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌលជាមួយក្រុមគ្រួសារពួកគាត់បន្ទាប់ពីបានស្តារ ពីថ្នាក់បឋមដល់វិទ្យាល័យ។

- យុវតីចំនួន៦នាក់បានប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ(ធ្លាក់១នាក់)ដោយជោគជ័យ និងបានបន្តអាហារូបករណ៍ឧត្តមសិក្សាសកលវិទ្យាល័យ។
- កុមារីចំនួន៥នាក់ បានបោះបង់ការសិក្សាក្នុងមូលហេតុផ្សេងៗ ដើម្បីជួយក្រុមគ្រួសារពួកគាត់។

- កុមារីចំនួន៦០នាក់ កំពុងបន្តអាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រោមណ្ឌល ជាមួយក្រុមគ្រួសារពួកគាត់។
- អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រោមណ្ឌល២០នាក់ បានការឧត្តម្ភកង់១នាក់ ១គ្រឿង។
- អាហារូបករណ៍ក្រោមឧត្តមសិក្សាស្នាក់នៅក្រៅមណ្ឌលចំនួន៧១នាក់ បានទទួលការសួរសុខទុក្ខ និងតាមដានបន្តចំនួន២០៧លើកពីកម្មវិធីអប់រំនិងបណ្តុះបណ្តាល។

ឧបត្ថម្ភសំភារសិក្សា



ឧបត្ថម្ភមធ្យោបាយធ្វើដំណើរទៅសាលា



សកម្មភាពចុះសួរសុខទុក្ខតាមដានបន្ត



## អាហារូបករណ៍ឧត្តមសិក្សាសកលវិទ្យាល័យ

### *យើងបាននិយាយថាយើងនឹងធ្វើ*

យើងបាននិយាយថានិស្សិត១៥នាក់ នឹងបានទទួលអាហារូបករណ៍ឧត្តមសិក្សានៅតាមសកលវិទ្យាល័យ។

### *លទ្ធផលយើងសម្រេចបាន*

និស្សិតចំនួន១៥នាក់ បានទទួលអាហារូបករណ៍ឧត្តមសិក្សា លើមុខវិជ្ជាផ្សេងៗ នៅតាមបណ្តាសកលវិទ្យាល័យនៅភ្នំពេញ:

- និស្សិត៤នាក់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រដោយជោគជ័យ លើជំនាញអក្សរសាស្ត្រអង់គ្លេស ទេសចរណ៍និងបដិសណ្ឋារកិច្ច អក្សរសាស្ត្រខ្មែរ និងគ្រប់គ្រង។ ឥឡូវពួកគាត់មានការងារធ្វើពេញម៉ោងដោយប្រើប្រាស់ជំនាញពួកគាត់បានសិក្សា។
- និស្សិត១នាក់ បានបោះបង់ការសិក្សា ដើម្បីធ្វើការរកប្រាក់ព្យាបាលម្តាយឈឺ។ ឥឡូវគាត់បានបន្តសិក្សាឧត្តមសិក្សាដោយទទួលខុសត្រូវខ្លួនឯង។
- និស្សិតចំនួន១០នាក់ កំពុងបន្តសិក្សាថ្នាក់ឧត្តមសិក្សានៅតាមសកលវិទ្យាល័យនៅភ្នំពេញ។

សកម្មភាពចុះឈ្មោះចូលរៀន



សកម្មភាពទៅមើលថ្នាក់



សកម្មភាពឧត្តមសិក្សាសកលវិទ្យាល័យ



## អាហារូបករណ៍ជំនាញវិជ្ជាជីវៈ

### យើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាយុវនារី១៥នាក់ នឹងបានទទួលអាហារូបករណ៍ជំនាញវិជ្ជាជីវៈសិក្សាជំនាញផ្សេងៗ។

### លទ្ធផលយើងសម្រេចបាន

យុវនារី១៦នាក់ បានទទួលអាហារូបករណ៍ជំនាញវិជ្ជាជីវៈ សិក្សាជំនាញផ្សេងៗពួកគាត់ស្រឡាញ់ពេញចិត្តៈ

- យុវនារីចំនួន៦នាក់ បានសិក្សាចប់លើជំនាញដែលពួកគាត់បានជ្រើសរើសដោយជោគជ័យ។
- យុវនារីចំនួន៥នាក់ បានបោះបង់ការសិក្សាជំនាញដោយមូលហេតុផ្សេងៗ។
- យុវនារីចំនួន៥នាក់ កំពុងបន្តសិក្សាជំនាញដែលពួកគាត់បានជ្រើសរើសស្រឡាញ់ពេញចិត្ត។

សកម្មភាពសិក្សាជំនាញអ៊ុតសក់





សកម្មភាពចុះសួរសុខទុក្ខនិងតាមដានបន្ត



## សកម្មភាពថ្នាក់ភាសាអង់គ្លេស

### យើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាកុមារីចំនួន៧០នាក់ នឹងបានទទួលការសិក្សាភាសាអង់គ្លេស។

### លទ្ធផលយើងសម្រេចបាន

កុមារីចំនួន៨៦នាក់ បានទទួលការសិក្សាភាសាអង់គ្លេស ក្នុងនោះ៧នាក់ ជានិស្សិតអាហារូបករណ៍ឧត្តមសិក្សាសកលវិទ្យាល័យ។ លទ្ធផលសម្រេចបានលើសផែនការ។

- កុមារី១៩នាក់ បានសិក្សាចប់សៀវភៅ Let's go 1 level (១២នាក់) ដោយជោគជ័យ ឡើងទៅបន្តសិក្សា Let's go 2 និង Super Mind II (៧នាក់) ឡើងទៅបន្តសិក្សា Super Mind III (unit 4)។

សកម្មភាពបង្រៀនក្នុងថ្នាក់ភាសាអង់គ្លេស







## សកម្មភាពថ្នាក់កុំព្យូទ័រ

### យើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាកុមារីចំនួន៨០នាក់ នឹងបានទទួលការសិក្សាកុំព្យូទ័រ។

### លទ្ធផលយើងសម្រេចបាន

កុមារីចំនួន៧៦នាក់ បានសិក្សាកុំព្យូទ័រ ក្នុងនោះ៧នាក់ជានិស្សិតឧត្តមសិក្សាសកលវិទ្យាល័យ។ លទ្ធផលសម្រេចបានតិចជាងផែនការរំពឹងទុក។

- កុមារី២៣នាក់ បានសិក្សាចប់កម្មវិធី MS Word (៨នាក់) Excel and PowerPoint (៦នាក់) និង Adobe Photoshop (៩នាក់) ដោយជោគជ័យ និងទទួលបានវិញ្ញាបនបត្របញ្ជាក់ការសិក្សា។

សកម្មភាពសិក្សាកុំព្យូទ័រ







## បណ្ណាល័យ

### យើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាកុមារីចំនួន៦០នាក់ នឹងចូលអានសៀវភៅ និងធនធានអប់រំផ្សេងៗ នៅក្នុងមណ្ឌលទុំឌី។

### លទ្ធផលយើងសម្រេចបាន

កុមារីចំនួន៨៦នាក់ បានចូលអានសៀវភៅ និងធនធានអប់រំផ្សេងៗនៅក្នុងបណ្ណាល័យនៅមណ្ឌលទុំឌី។ ចំនួនកុមារីចូលអានសៀវភៅនិងធនធានអប់រំផ្សេងៗលើសផែនការរំពឹងទុក។

សកម្មភាពផ្សេងៗនៃការអាននិងរៀននៅក្នុងបណ្ណាល័យ







## កម្មវិធីលើកកម្ពស់សេដ្ឋកិច្ច

ទិសដៅសំខាន់សម្រាប់យុវនារី-កុមារីម្នាក់ៗ គឺសម្រេចឱ្យបានស្វ័យឯករាជ្យភាព។ នៅដំណាក់កាលនេះ យុវនារី-កុមារីដែលទទួលផលពីកម្មវិធី គឺកាត់បន្ថយការពឹងផ្អែកលើអង្គការអាហ្វេស៊ីប ព្រោះពួកគាត់អាចមានលទ្ធភាពផ្តល់ឱ្យវិញខ្លះៗ តាមរយៈការជួយដល់យុវនារី-កុមារីដទៃទៀត ដែលកំពុងឆ្ពោះមកកាន់ដំណាក់កាលនេះដែរ។ នៅពេលយុវនារី-កុមារីមានវឌ្ឍនភាពលើការស្តារនីតិសម្បទា អប់រំ និងបណ្តុះបណ្តាល គឺយើងចាប់ផ្តើមនីតិវិធីនៃការធ្វើសមាហរណកម្មពួកគាត់ទៅកាន់ជីវិតធម្មតានៃការរស់នៅតាមសហគមន៍វិញ ក្នុងន័យនេះគឺផ្តោតលើការធ្វើជាកូនជាង ឬហាត់ការ ឬបង្កើតមុខរបរខ្លួនឯង។

### ហេតុអ្វីបានជាយើងធ្វើការងារនេះ?

យុវនារីចាប់ផ្តើមធ្វើការជាកូនជាង ឬហាត់ការ ឬបង្កើតមុខរបរខ្លួនឯង ដោយប្រើប្រាស់ជំនាញដែលពួកគាត់បានសិក្សាដើម្បីរកប្រាក់ចំណូល។ ពួកគាត់ចាប់ផ្តើមរៀនរស់នៅដោយឯករាជ្យ គ្រប់គ្រងថវិកានិងការចំណាយផ្សេងៗខ្លួនឯង ដែលជាចំណុចចាប់ផ្តើមធ្វើឱ្យបានសម្រេចនូវឯករាជ្យភាពហិរញ្ញវត្ថុ តាមរយៈនិរន្តភាពអាជីព(មុខរបរ)។

### តេធ្វើឱ្យមានភាពខុសគ្នាអ្វីខ្លះ?

យុវនារីចំនួន១៧នាក់ ដែលបានបញ្ចប់ការសិក្សាដោយជោគជ័យលើជំនាញដែលពួកគាត់បានជ្រើសរើស ដោយការស្រឡាញ់ពេញចិត្ត បានសមាហរណកម្មជាមួយការងារ និងបង្កើតមុខរបរ ដូចជាបុគ្គលិកថែទាំ កម្មការនីរោងចក្រ ធ្វើភេសជ្ជៈ ជាងអ៊ុតសក់ លក់ដូរ គ្រូបង្រៀន រត់តុ និងលក់ភេសជ្ជៈ ជាដើម។

### យើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថាយុវនារីចំនួន១៤នាក់ នឹងសមាហរណកម្មជាមួយការងារនិងអាជីវកម្មខ្នាតតូច បន្ទាប់ពីពួកគាត់បានសិក្សាចប់មុខជំនាញបានជ្រើសរើស។

### លទ្ធផលយើងសម្រេចបាន

យុវនារីចំនួន១៧នាក់ បានសមាហរណកម្មជាមួយការងារ និងមុខរបរខ្នាតតូច។ ក្នុងនោះ២នាក់បានសមាហរណកម្មជាមួយមុខរបរ និង១៥នាក់ បានសមាហរណកម្មជាមួយការងារ។ ៣នាក់បានសមាហរណកម្មស្ពាន និង១៤នាក់ សមាហរណកម្មសាកល្បង។

- កុមារីចំនួន៨០នាក់ បានទៅលេងគ្រួសារចំនួន១៤៧លើក។ ការទៅលេងគ្រួសារចំនួន១១៧ លើកជាការទៅលេងគ្រួសារនៅតាមសហគមន៍ និង ៣០លើក គ្រួសារមកលេងនៅមណ្ឌលទុំឌី។
- កុមារីស្នាក់នៅក្នុងមណ្ឌលចំនួន៤១នាក់បានទទួលការកត់ត្រាព័ត៌មានអំពីផែនការអនាគត។
- យុវនារី-កុមារីសមាហរណកម្មចំនួន៨៩នាក់ បានទទួលការតាមដានបន្តចំនួន២៧៩លើក តាមការចុះជួបផ្ទាល់ និងតាមរយៈទូរស័ព្ទ។

បង្កើតមុខរបរខ្នាតតូច



ជាមួយការងារ



សកម្មភាពចុះតាមដានបន្ត



# កម្មវិធីបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ (សែន)

កម្មវិធី**សែន**គឺជាការចងក្រងបណ្តុំសមាជិកក្រុម ដែលបានស្តារ ជាសះស្បើយពីរបួសផ្លូវកាយ និងផ្លូវចិត្តដោយជោគជ័យ និងបានធ្វើសមាហរណកម្មទៅតាមសហគមន៍វិញ នៅទូទាំងប្រទេសកម្ពុជា ក្នុងគោលបំណងលើកទឹកចិត្ត និងលើកកម្ពស់សុខមាលភាពសង្គមដល់អតីតជនរងគ្រោះ បញ្ជ្រាប និងបង្កើនការយល់ដឹងដល់សាធារណៈជនទូទៅ ដើម្បីស្វែងរកដំណោះស្រាយឱ្យបានប្រសើរ។ សមាជិក**សែន**នីមួយៗដើរតួនាទីយ៉ាងសំខាន់ ជាអ្នកធ្វើការផ្លាស់ប្តូរនៅតាមសហគមន៍របស់ពួកគាត់ តាមរយៈការពាំនាំសម្លេងរបស់ជនរងគ្រោះស្វែងរកដំណោះស្រាយ។

## ហេតុអ្វីបានជាយើងធ្វើការងារនេះ?

កម្មវិធី**សែន**បានបញ្ចូលសហសម្លេងរបស់សមាជិកជាផែនការសកម្មភាពទិសដៅ ស្របតាមគោលដៅគន្លឹះ *"លើកទឹកជនរងគ្រោះ ឱ្យក្លាយជាអតីតជនរងគ្រោះ និងលើកទឹកចិត្តអតីតជនរងគ្រោះ ឱ្យក្លាយជាផ្នែកមួយ នៃដំណោះស្រាយ"*។ អតីតជនរងគ្រោះគឺជាអ្នកធ្វើការផ្លាស់ប្តូរដើម្បីធ្វើមនៅក្នុងវិស័យការងារនេះ ពួកគាត់ជានិមិត្តរូប ដែលអាចឱ្យជនរងគ្រោះដទៃទៀត យកគំរូតាម នូវវីរភាពអង់អាចក្លាហានរបស់ពួកគាត់។

## តើធ្វើឱ្យមានភាពខុសគ្នាអ្វីខ្លះ?

កម្មវិធីសែនមានសមាជិកសរុបចំនួន៣៧នាក់ ក្នុងនោះ១៦នាក់ ជាសមាជិកចុងគ្រាឆ្នាំមុន និង២១នាក់ទៀត ជាសមាជិកថ្មីឆ្នាំ២០២២។

### យើងបាននិយាយថាយើងនឹងធ្វើ

យើងបាននិយាយថានឹងជ្រើសសមាជិក៥០នាក់។

### លទ្ធផលយើងសម្រេចបាន

យើងបានរៀបចំប្រជុំអាហារសាមគ្គី៣លើក ជាមួយសមាជិកសែនចំនួន៣៧។ ក្នុងនោះប្រជុំ១លើក នៅទីក្រុងភ្នំពេញ និងប្រជុំ២លើកទៀត នៅខេត្តសៀមរាប ។ ទិសដៅនៃការប្រជុំសមាជិកគឺដើម្បីផ្លាស់ប្តូរបទពិសោធន៍គ្នា បញ្ហាប្រឈម បច្ចុប្បន្នភាពការងារកម្មវិធីសែន និងពង្រឹងទំនាក់ទំនងសមាជិក។

- កុមារីបានរៀបចំបោះឆ្នោត ប្រចាំឆ្នាំ១លើក នៅមណ្ឌលទុំឌី ដើម្បីជ្រើសរើសប្រធានក្រុមដឹកនាំតាមឆន្ទៈរបស់ពួកគាត់ ជាតំណាងពួកគាត់ ក្នុងការស្នើសុំទាមទារនូវតម្រូវការរបស់ពួកគាត់នៅក្នុងមណ្ឌល។ ជាលទ្ធផលកុមារីចំនួន៦នាក់ ត្រូវជាប់ឆ្នោតជ្រើសរើសជាមេក្រុមដឹកនាំ។
- កុមារីចំនួន១១៩នាក់ បានបន្តទទួលប្រាក់ឧបត្ថម្ភប្រចាំខែពី**សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។
- បានប្រជុំចំនួន១៦លើក ក្នុងនោះ៤លើកប្រជុំជាមួយមេក្រុមដឹកនាំ ក្នុងគោលបំណងជួយពង្រឹងសកម្មភាពប្រចាំថ្ងៃ និង១២លើកទៀត ប្រជុំជាមួយកុមារីទូទៅដែលកំពុងស្នាក់ក្នុងមណ្ឌល។

សកម្មភាពបទបង្ហាញការងារសែន



សកម្មភាពបំពេញទម្រង់សមាជិក



សកម្មភាពអាហារសាមគ្គី



# អំពីបុគ្គលិក និងការគ្រប់គ្រងគម្រោង

## បុគ្គលិក

មានបុគ្គលិកចំនួន៣៦នាក់ បម្រើការនៅអង្គការ អាហ្វេស៊ីប កម្ពុជា ក្នុងឆ្នាំ២០២២ ក្នុងនោះនារី២១នាក់ និងបុរស១៥នាក់។ ៨០%នៃបុគ្គលិកនារីជាអតីតជនរងគ្រោះ។ ការងារយើងលើកទឹកជនរងគ្រោះ ឱ្យក្លាយជាអតីតជនរងគ្រោះ និងលើកទឹកចិត្តអតីតជនរងគ្រោះ ឱ្យក្លាយជាផ្នែកមួយ នៃដំណោះស្រាយ ព្រោះអតីតជនរងគ្រោះ គឺជាអ្នកធ្វើការផ្លាស់ប្តូរដំផ្ទើមនៅក្នុងវិស័យការងារនេះ ពួកគាត់ជានិមិត្តរូប ដែលអាចឱ្យជនរងគ្រោះដទៃទៀត យកគំរូតាម នូវវីរភាពអង់អាចក្លាហានរបស់ពួកគាត់។ បុគ្គលិកជាអតីតជនរងគ្រោះ បច្ចុប្បន្នកំពុងកាន់តួនាទីការងារជាសមាជិកគណៈគ្រប់គ្រងជាន់ខ្ពស់ សហនាយកកម្មវិធី ប្រធានកម្មវិធីបណ្តាញលើកកម្ពស់អតីតជនរងគ្រោះ ប្រធានមណ្ឌលនិងគិលានុបដ្ឋាយិកា ប្រធានកម្មវិធីអប់រំនិងបណ្តុះបណ្តាល អ្នកសម្របសម្រួលអាហារូបករណ៍ឧត្តមសិក្សានិងជំនាញវិជ្ជាជីវៈ ប្រធានផ្នែកចិត្តសាស្ត្រ ប្រធានកម្មវិធីលើកកម្ពស់សេដ្ឋកិច្ច បុគ្គលិកថែទាំ ចុងភៅ បុគ្គលិកហិរញ្ញវត្ថុ អ្នកសម្របសម្រួលឪពុក-ម្តាយធម៌ ជំនួយការផ្នែកនីតិកម្ម ស្ថិតិនិងបញ្ចូលទិន្នន័យ។

## ការគ្រប់គ្រងគម្រោង

ការប្រជុំប្រធានកម្មវិធីនិងផ្នែកប្រចាំខែ ១ខែ២លើក បានប្រព្រឹត្តិទៅជាទៀងទាត់ ក្នុងគោលបំណងចែករំលែកវឌ្ឍនភាពការងាររបស់កម្មវិធីនីមួយៗ ទទួលរបាយការណ៍ត្រឡប់វិញអំពីសកម្មភាពការងារតាមដានបន្តកាលពីប្រជុំលើកមុន ទទួលបច្ចុប្បន្នភាពថ្មីៗ បង្កើតឧបករណ៍ឬក្រុមការងារតាមតម្រូវការជាក់ស្តែង បង្កើតគម្រោងផែនការសកម្មភាពត្រូវធ្វើបន្ទាប់សម្រាប់សកម្មភាពជាក់លាក់ណាមួយ។ល។ ការប្រជុំនេះជាផ្នែកមួយនៃការកសាងស្មារតីក្រុមការងារ សមត្ថភាពបុគ្គលិក និងបង្កើនគុណភាពការគ្រប់គ្រងសម្រាប់បុគ្គលិក។ តាមកម្មវិធីនីមួយៗបានរៀបចំប្រជុំបុគ្គលិកប្រចាំសប្តាហ៍ ក្នុងគោលបំណងដូចគ្នា។

ជារៀងរាល់ខែ ប្រធានកម្មវិធីនិងផ្នែកនីមួយៗត្រូវធ្វើផែនការសកម្មភាពនិងថវិកា សម្រាប់ការអនុវត្តសកម្មភាពការងារកម្មវិធីនិងផ្នែករបស់ខ្លួន ដោយអនុលោមតាមផែនការមេ ដាក់ជូនប្រធានខ្សែបណ្តោយពិនិត្យសម្រេច ជារៀងរាល់ថ្ងៃទី២៥នៃចុងខែនីមួយៗ និងធ្វើរបាយការណ៍សកម្មភាពការងារកម្មវិធីដែលបានអនុវត្តដាក់ជូនប្រធានខ្សែបណ្តោយជារៀងរាល់សប្តាហ៍ទី១នៃខែបន្ទាប់។ ជារៀងរាល់សប្តាហ៍ទី៤ប្រចាំខែ បុគ្គលិកកម្មវិធីនិងផ្នែកនីមួយៗត្រូវធ្វើបច្ចុប្បន្នភាពកំណត់ត្រាការងារ ចូលក្នុងសំណុំឯកសារ ដើម្បីបញ្ចូលស្ថិតិក្នុងប្រព័ន្ធទិន្នន័យកុំព្យូទ័រសម្រាប់ធ្វើរបាយការណ៍ផ្ទៃក្នុង និងរបាយការណ៍ផ្ញើចេញក្រៅ។



# ក្រុមប្រឹក្សាភិបាល



**លោក ក្លូដ ហ៊ីលដែនប្រែន្ទ**

ប្រធានក្រុមប្រឹក្សាភិបាល
អនុប្រធាន មូលនិធិសូលីណា
ស្ថាបនិកក្រុមហ៊ុន វីនី & វីនី ហ្សា



**ក. អាណាលីន ម៉ខ័ដ**

សមាជិកក្រុមប្រឹក្សាភិបាល
តារាភាពយន្ត
សកម្មជនសិទ្ធិមនុស្ស



**លោក ដេវីដ យុក្ខ**

សមាជិកក្រុមប្រឹក្សាភិបាល
នាយកប្រតិបត្តិ អ៊ីអេសជី
ទីប្រឹក្សា



**លោកស្រីម៉ម សុម៉ាលី**

សមាជិកក្រុមប្រឹក្សាភិបាល
សកម្មជនសិទ្ធិមនុស្ស
ស្ថាបនិកនិងនាយិកាគ្រប់គ្រ



**លោកស្រី ខ៊ាន់ ស៊ីណា**

សមាជិកក្រុមប្រឹក្សាភិបាល
សកម្មជនសិទ្ធិមនុស្ស
ប្រធានកម្មវិធីអតីតជនរងគ្រោះ

# ម្ចាស់ជំនួយ

## រាជរដ្ឋាភិបាលកម្ពុជា

**បន្តជួយ**

- អង្ករ១៤,៤តោនសម្រាប់រយៈពេល១២ខែ។
- ១២០,០០០,០០០.00រៀលឧបត្ថម្ភម្ហូបប្រចាំថ្ងៃសម្រាប់រយៈពេល១២។
- ១៤២,៨០០,០០០.០០រៀលឧបត្ថម្ភប្រាក់ហោប៉ៅប្រចាំខែដល់កុមារី១១៩នាក់សម្រាប់រយៈពេល១២ខែ។
- ៣០,០០០,០០០.០០រៀលកាកបាតក្រហមកម្ពុជាឧបត្ថម្ភម្ហូបអាហារសម្រាប់រយៈពេល១២ខែ។

Foundation SOLYNA Saving children from sexual traffic

PROJECT FUTURES TRANSFORMING LIVES

កាកបាទក្រហមកម្ពុជា CAMBODIAN RED CROSS

HEART MOTHERS Sending love to child survivors of sex trafficking

THE ORPHANED STARFISH FOUNDATION

សម្រស់ធម្មជាតិ

DAUN PENH CAMBODIA GROUP

**សប្បុរសជន**

## ការបរិច្ចាគជាសម្ភារ

- ក្រុមហ៊ុនHSCបានលាបថ្នាំថ្មីបណ្ណាល័យ២បន្ទប់ សៀវភៅអានផ្សេងៗជាភាសាខ្មែរ តុ កៅអី កង្ហា អំពូលភ្លើង។
- ធនាគារហិរញ្ញវត្ថុNongHyup កូរ៉េ បានឧបត្ថម្ភកុំព្យូទ័រលើតុចំនួន៥គ្រឿងសម្រាប់ថ្នាក់រៀនកុំព្យូទ័រ។
- ក្រុមហ៊ុនHangzhou Hikvision Digital Technology ឧបត្ថម្ភកុំព្យូទ័រយួរដៃចំនួន៦គ្រឿង flat panel៦៥អ៊ីង ១គ្រឿង digital signage១គ្រឿង webcam២០ឯកតា និងSSDចំនួន១០០សន្លឹក ដល់អង្គការអាហ្វេស៊ីប។

